**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០០៨/២០.....................**ក.ប/សរ.ណា.ន.ខ.ល**

# សេចក្តីណែនាំ
# ស្តីពី
# ការរក្សាអាថ៌កំបាំងវិជ្ជាជីវៈរបស់មន្ត្រីអធិការកិច្ចការងារ

កន្លងមក ក្រសួងបានទទួលរបាយការណ៍ពីវិស័យឯកជនថា មានមន្ត្រីក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើឱ្យបែកធ្លាយនូវព័ត៌មានសម្ងាត់ផលិតកម្ម អាជីវកម្ម ឬឯកជន ដែលផ្ទុយនឹងកថាខណ្ឌទី២ មាត្រា៣៤៣ នៃច្បាប់ស្តីពីការងារ ដែលចែងថា "*មុននឹងទទួលការតែងតាំង អធិការនិងអគ្គិបាលការងារ ត្រូវស្បថថានឹងបំពេញភារកិច្ចរបស់ខ្លួនដោយល្អ ដោយស្មោះត្រង់ និងមិនប្រាប់ឱ្យគេដឹងនូវអាថ៌កំបាំងផលិតកម្ម ពាណិជ្ជកម្ម ឬរបៀបធ្វើអាជីវកម្មដែលខ្លួនបានដឹងក្នុងពេលបំពេញមុខការខ្លួន ទោះបីខ្លួនចេញពីក្រសួងហើយក្តី*"។

មាត្រា៣៨៦ នៃច្បាប់ស្តីពីការងារ ចែងថា "*ដោយមិនគិតដល់ទោសពិន័យ ដែលចែងក្នុងលក្ខន្តិកៈនៃភ្នាក់ងាររាជការ អធិការនិងអគ្គិបាលការងារ ព្រមទាំងអធិការពេទ្យការងារដែលបើកកកាយធ្វើឱ្យបែកការសម្ងាត់និងរបៀបផលិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយថ្ងៃទៅមួយខែ ទោះបីការបើកកកាយនោះ បានធ្វើនៅពេលក្រោយដែលបានឈប់កាន់មុខងារហើយក៏ដោយ*"។ ក្នុងន័យនេះ ដើម្បីរក្សាបាននូវសេចក្តីថ្លៃថ្នូរ និងក្រមសីលធម៌សម្រាប់មន្ត្រីអធិការកិច្ចការងារ ក្រសួងសូមធ្វើការណែនាំដល់គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួង និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវរក្សាឱ្យបាននូវការសម្ងាត់អំពីព័ត៌មានអាជីវកម្ម របៀបផលិត និងព័ត៌មានឯកជននានា ទោះបីនៅពេលក្រោយដែលបានឈប់កាន់មុខងារហើយក៏ដោយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទាំងអស់ និងគ្រប់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

ថ្ងៃ សុក្រ ១៣រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល** :

-គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួង

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

"ដើម្បីជ្រាប និងអនុវត្ត"

-ឯកសារ កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥*